


# «ជ្រុងមួយនៃបេតិកភណ្ឌវប្បធម៌សិល្បៈអរូបីខ្មែរ»

# One Corner of Intangible Culture Heritage of Cambodia

*ដោយៈ*

*លោក* **គុល សារូ**

*អនុប្រធានមជ្ឈមណ្ឌលស្រាវជ្រាវវប្បធម៌វិទ្យាសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ*

*២០១៨*

# សន្និសីទអន្តរជាតិ
# ស្តីពី
# «តម្លៃវប្បធម៌អាស៊ីប៉ាស៊ីហ្វិកៈ វប្បធម៌, ប្រវត្តិ និងអនាគតភាព»

*ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨, ក្រុងសៀមរាប, ខេត្តសៀមរាប*

## «ជ្រុងមួយនៃបេតិកភណ្ឌវប្បធម៌សិល្បៈអរូបីខ្មែរ»

**ONE CORNER OF INTANGIBLE CULTURAL HERITAGE OF CAMBODIA**


*ដោយៈ*

សាស្ត្រាចារ្យ **កុល សារុ**

*អនុប្រធានមជ្ឈមណ្ឌលស្រាវជ្រាវវប្បធម៌វិទ្យាសាស្ត្រ*

*នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ*


**១-សេចក្តីផ្តើម** (Introduction)

ប្រទេសកម្ពុជា គឺជាមហាប្រទេសដ៏មានចំណាស់មួយនៅតំបន់អាស៊ីអាគ្នេយ៍ សម្បូរហូរហៀរទៅដោយសម្បត្តិសិល្បៈវប្បធម៌ទាំងពីរៈ សម្បត្តិវប្បធម៌លទ្ធកម្ម និងសម្បត្តិវប្បធម៌ធម្មជាតិ។ កេរដំណែលដ៏មានតម្លៃមិនអាចកាត់ថ្លៃបានដូចជាៈ កុលាលភាជន៍ សំណង់ប្រាសាទ វត្តអារាម បដិមា សិលាចារិក គម្ពីរ សាស្ត្រា តន្ត្រី ចម្រៀង របាំគ្រប់ទម្រង់ ល្ខោនគ្រប់ទម្រង់ កំណាព្យ អក្សរសិល្ប៍។ល។ បានធ្វើឱ្យកម្ពុជាល្បីរន្ទឺទូទាំងពិភពលោកនៃសម័យកាលប្រវត្តិសាស្ត្រ។ តាមរយៈសម្បត្តិបេតិកភណ្ឌវប្បធម៌សិល្បៈខ្មែរដ៏អស្ចារ្យទាំងនេះ បេតិកភណ្ឌវប្បធម៌សិល្បៈនៃមនុស្សជាតិ មានជាអាទិ៍ៈ តំបន់អង្គរ ប្រាសាទព្រះវិហារ ប្រាសាទសំបូរព្រៃគុក របាំក្បាច់បុរាណ ល្ខោនស្បែកធំ ល្បែងទាញព្រ័ត្រ ចាប៉ីដងវែង និងល្ខោនខោល។ ទន្ទឹមនេះសម្បត្តិបេតិកភណ្ឌវប្បធម៌មួយចំនួនទៀតក៏កំពុងរៀបចំឯកសារ ដើម្បីស្នើសុំចុះបញ្ជីនៅអង្គការយូណេស្កូជាបន្តបន្ទាប់ទៀត។

យោងទៅលើអនុសញ្ញាឆ្នាំ២០០៣ មរតកវប្បធម៌អរូបី គឺសំដៅទៅលើការប្រតិបត្តិ ការបង្ហាញការសម្តែងចេញមកចំណេះដឹង ជំនាញ (ក្នុងនោះរួមបញ្ចូលទាំងឧបករណ៍ ប្រដាប់ប្រដា វត្ថុ និងទីតាំងវប្បធម៌ដែលជាប់ពាក់ព័ន្ធ) ដែលសហគមន៍ ក្រុមមនុស្ស ឬបុគ្គលទទួលស្គាល់ថាជាមរតកវប្បធម៌របស់ខ្លួន ហើយបានផ្ទេរបន្តពីជំនាន់មួយទៅជំនាន់មួយទៀត ហើយត្រូវសហគមន៍ ឬក្រុមមនុស្សយកមកប្រតិបត្តិឡើងវិញជាប់រហូតមក ដើម្បីឆ្លើយតបនឹងបរិស្ថានរស់នៅប្រាស្រ័យទាក់ទងជាមួយធម្មជាតិ និងប្រវត្តិរឿងរ៉ាវរបស់ពួកគេ ព្រមទាំងផ្តល់ឱ្យសហគមន៍នោះ

នូវអត្តសញ្ញាណ និងនិរន្តរភាពផង[1]។ ហេតុដូច្នេះ**បេតិកភណ្ឌវប្បធម៌សិល្បៈអរូបីខ្មែរ** បានលើកកម្ពស់ដល់ការគោរព នូវវប្បធម៌ចម្រុះ និងការច្នៃប្រឌិតរបស់មនុស្ស ។

## ២- បេតិកភណ្ឌជាអ្វី? ( What is Heritage ? )

បេតិកភណ្ឌ ត្រូវបានគេកំណត់ថា ជាចលនៈ ឬអចលនៈទ្រព្យ ដែលមានសារៈសំខាន់ធំធេង ដែលជាមរតកវប្បធម៌របស់មនុស្សគ្រប់រូប ឬជាវត្ថុដែលជាការបង្ហាញនូវសក្ខីភាពនៃស្នាដៃរបស់មនុស្ស ឬជាការវិវឌ្ឍរបស់ធម្មជាតិ ហើយដែលនាំមកនូវសារប្រយោជន៍ និងតម្លៃខាងបុរាណវិទ្យា ប្រវត្តិវិទ្យា សិល្បៈ វិទ្យាសាស្ត្រ ឬក៏បច្ចេកទេស ភាពសម្បូណ៌ទៅដោយសម្បត្តិបេតិកភណ្ឌវប្បធម៌សិល្បៈទាំងរូបី និងអរូបី ដែលបុព្វបុរសបានបន្សល់ទុករាប់ពាន់ឆ្នាំមកហើយស័ក្តិសមជា «**ព្រះរាជាណាចក្រនៃវប្បធម៌**» ដ៏ពិតប្រាកដ។ លើសពីនេះតាមរយៈការខិតខំប្រឹងប្រែងជាប់មិនដាច់របស់រាជរដ្ឋាភិបាល សម្បត្តិវប្បធម៌កម្ពុជា មួយចំនួនត្រូវបានពិភពលោកទទួលស្គាល់ និងដាក់បញ្ចូលជាបេតិកភណ្ឌពិភពលោក។ ប្រជាជនកម្ពុជាគ្រប់រូបមានហេតុផលគ្រប់គ្រាន់ និងភ័ស្តុតាងជាក់ច្បាស់ប្រកបដោយមោទនភាពចំពោះទេពកោសល្យដ៏កំពូលប្រណីតភាព សោភ័ណភាព និងអច្ឆរិយដែលដូនតាខ្មែរបានបន្សល់ទុកឱ្យជាមរតកវប្បធម៌ដ៏មានតម្លៃមហាសាលមិនអាចកាត់ថ្លៃបាន កំណត់ឱ្យយើងនូវអត្តសញ្ញាណជាតិ និងនិរន្តរភាពដោយផ្សារភ្ជាប់ទំនាក់ទំនងប្រជាជនកម្ពុជាពីអតីតកាល មកបច្ចុប្បន្ន និងទៅអនាគត ហើយក៏ជាប្រភពធនធានមិនចេះរីងស្ងួតក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចសង្គម[2]។

### ក-បេតិកភណ្ឌរូបី (Tangible Heritage)

ប្រាសាទ វិមាន ចម្លាក់ គំនូរ សិលាចារិក រូង ជាកន្លែងសំណាក់មនុស្សដើម។ រូងភ្នំដែលមានរូបរាងជាអ្វីមួយ មានតម្លៃជាប្រវត្តិសាស្ត្រ សិល្បៈ វិទ្យាសាស្ត្រ ឬសាសនា។ ក្រុមអគារសង់ជាប់គ្នា ឬសង់ដាច់ពីគ្នាក្នុងលំហទិដ្ឋភាពមួយមានតម្លៃជាប្រវត្តិសាស្ត្រ សិល្បៈ វិទ្យាសាស្ត្រ ឬសាសនា។ បណ្តាបេតិកភណ្ឌវប្បធម៌ទាំងនោះរួមមានផ្នែករូបី ជាអាទិ៍គឺ ប្រាសាទ រមណីយដ្ឋាន វត្តអារាម ផ្ទះបុរាណ រមណីយដ្ឋានប្រវត្តិសាស្ត្រ ទួលអង្គ... រួមមានរាប់រយរាប់ពាន់ ប្រមាណជិត៤០០០កន្លែង រាយដេរដាសទូទាំងប្រទេស (នេះមិនទាន់គិតដល់ប្រាសាទរាប់សិប ឬរាប់រយផ្សេងទៀតដែលជាអតីតប្រាសាទបុរាណខ្មែរ ស្ថិតនៅក្នុងដែនដីប្រទេសជិតខាងទៀតផង)[3]។ បេតិកភណ្ឌរូបីដែលយើងបានបញ្ចូលជាសម្បត្តិបេតិកភណ្ឌពិភពលោករួមមាន៖

១) តំបន់អង្គរ ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩២

២) ប្រាសាទព្រះវិហារ ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៨

៣) ប្រាសាទសម្បូណ៌ព្រៃគុក ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៧

### ខ-បេតិកភណ្ឌអរូបី (Intangible Heritage)

ការប្រតិបត្តិ ការសម្តែង ការនិយាយ ចំណេះដឹង ចំណេះធ្វើ ព្រមទាំងឧបករណ៍ វត្ថុដែលមានប្រភពនិងលំហវប្បធម៌បញ្ចូលគ្នាបន្តពីជំនាន់មួយទៅជំនាន់មួយ ហើយត្រូវបានបង្កើតថ្មីជាអចិន្ត្រៃយ៍ឡើងវិញតាមបរិស្ថាន

---

[1] ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បញ្ជីសារពើភណ្ឌអរូបី ឆ្នាំ២០១៨

[2] ហ៊ុន សែន សារលិខិត ថ្ងៃទី៨ មិថុនា ២០១៧

[3] ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បញ្ជីសារពើភណ្ឌអរូបី ឆ្នាំ២០១៨

ដែលគេរស់នៅទៅនិងអន្តរកម្មរបស់ពួកគេជាមួយនឹងធម្មជាតិ ជាមួយនឹងប្រវត្តិសាស្ត្រដែលសហគមន៍ ក្រុមមនុស្ស និងក្នុងករណីខ្លះបុគ្គលស្គាល់ថាជាផ្នែកមួយនៃបេតិកភណ្ឌវប្បធម៌របស់ពួកគេ។ របស់ដែលសមស្របជាមួយ និង លិខិតូបករណ៍អន្តរជាតិ កំពុងមានអត្ថិភាពទាក់ទងជាមួយនឹងសិទ្ធិមនុស្សជាធរមាន តម្រូវឱ្យមានការគោរពគ្នាទៅវិញទៅមករវាងសហគមន៍ ក្រុមមនុស្ស បុគ្គល ហើយរួមគ្នាអភិវឌ្ឍន៍ដោយឈរលើមូលដ្ឋានអភិរក្ស ទើបមាននិរន្តរភាពនិងចីរភាព។

បង្ហាញពីទិដ្ឋភាពទូទៅនៃទម្រង់សិល្បៈអរូបី នៅកម្ពុជាមានជាអាទិ៍៖ របាំគ្រប់ទម្រង់ ល្ខោនក្បាច់បុរាណ (ល្ខោនព្រះរាជទ្រព្យ ឬល្ខោនលួង) ល្ខោនតុក្កតា ល្ខោនស្បែកតូចឬអាយ៉ង ល្ខោនស្បែកធំ ល្ខោនស្បែកពណ៌ ល្ខោនប្រាមោជ្ជទ័យ ល្ខោនកំណាព្យ ល្ខោនភ្លេងការ ល្ខោនអាប៉េ អាយ៉ៃរឿង ខ្សែដៀវរឿង ចាប៉ីរឿង ល្ខោនខោល ល្ខោនពោលស្រី ល្ខោនបើកបទ ល្ខោនមហោរី ល្ខោនគែន ល្ខោនយីកេ ល្ខោននិយាយ ល្ខោនបាសាក់ និទានរឿង សៀករឿង និងល្ខោនចម្រុះ ដែលបេតិកភណ្ឌអរូបីទាំងនេះត្រូវបានពិភពលោកដាក់បញ្ចូលជាសម្បត្តិបេតិកភណ្ឌមនុស្សជាតិបានមួយចំនួនដូចជា៖

១) របាំអប្សរា ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០០៣

២) ល្ខោនស្រមោលស្បែកធំ ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៥

៣) ល្បែងទាញព្រ័ត្រ ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៥

៤) ចម្រៀងចាប៉ី ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦

៥) ល្ខោនខោល ថ្ងៃពុធ ទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨

**បញ្ហាសិល្បៈវប្បធម៌អរូបី** (The issues of intangible cultural art)

បញ្ហាសិល្បៈវប្បធម៌ អរិយធម៌របស់ប្រជាជាតិនីមួយៗ តែងហូរឆ្លងចេញចូលទទួលឥទ្ធិពលពីគ្នាទៅវិញទៅមក។ ខ្មែរជាពូជអ្នកលេងល្បែងបញ្ញា គ្មានគំនិតគិតប៉ុនប៉ង ចម្លង ផ្ដិតយកពីគេទាំងស្រុង ទាំងដុល ឬទាំងឫសគល់នោះឡើយ។ អ្វីដែលចូលមកស្រុកខ្មែរ ត្រូវតែឆ្លងកាត់ ត្បាល់កិនសិន គឺទាល់តែបានកិន បានចម្រាញ់ បានជម្រើស បានជម្រុះ...ជ្រើសយកតែជាតុណាដែលជាភាពប្រពៃ ភាពមានប្រយោជន៍សម្រាប់ខ្មែរ និងដើម្បីខ្មែរតែប៉ុណ្ណោះ ទើបខ្មែរព្រមទទួលយកធ្វើជារបស់ខ្មែរ ដូច្នេះការកសាងវប្បធម៌សិល្បៈមួយឱ្យមានបុគ្គលិកលក្ខណៈជាតិពិតប្រាកដ មិនអាចធ្វើទៅបានក្នុងរយៈពេលតិចជាង១០០ឆ្នាំឡើយ។ <u>ឧទាហរណ៍</u>៖ ល្ខោនបាសាក់ចូលមកស្រុកខ្មែរ ប្រហែលជាក្នុងឆ្នាំ១៩៣០ (ពេលនេះ៨៨ឆ្នាំ) តែមធ្យោបាយសម្ដែងរបស់ល្ខោនបាសាក់ ចម្រៀង តន្ត្រី សម្លៀកបំពាក់ នៅតែមានពណ៌សម្បុរចម្រុះ ទទួលឥទ្ធិពលពីចិន ពីបារាំង វៀតណាមនៅឡើយ។ រីឯពណ៌សម្បុរជាតិខ្មែរមានប្រហែល ៧០ភាគរយប៉ុណ្ណោះ។ ប្រាសាទ និងចម្លាក់ខ្មែរ បានរកបុគ្គលិកលក្ខណៈខ្មែរពិតប្រាកដឃើញចាប់ផ្ដើមពីសតវត្សរ៍ទី៩-១៣ បានន័យថាជាង៤០០ឆ្នាំ ទើបរកឃើញបុគ្គលិកលក្ខណៈជាតិពិត[4]។ ដូច្នេះការកសាងសមត្ថភាពនិងបណ្ដុះធនធានមនុស្សផ្នែកវប្បធម៌សិល្បៈគឺជាកត្តាចាំបាច់។ <u>ឧទាហរណ៍៖</u> អាណាចក្រអង្គរជាសរណដ្ឋានដ៏ពិសិដ្ឋ មានអរិយធម៌ខ្ពង់ខ្ពស់ មានទេពកោសល្យ ឧបនិស្ស័យនិងគំនិតច្នៃប្រឌិតខ្ពស់ ព្រមទាំងមានការលូតលាស់ខាងបញ្ញាដល់កំពូលនាសតវត្សរ៍ទី១១ និង១២ មានប្រាសាទធ្វើអំពីថ្មចំនួន១០៨០ ជាភ័ស្តុតាង មហាវិទ្យាល័យពីរ គឺជ័យ

[4] ឆេង ផុន គោលទស្សនៈធំៗ ចំពោះវប្បធម៌ខ្មែរ និងការអភិវឌ្ឍ ឆ្នាំ២០០០

ស្រី និងរាជវិហារ(សតវត្សរ៍ទី១១-១២)មានសាស្ត្រាចារ្យចំនួន ២៧៤០នាក់ មានបណ្ឌិត១៨អង្គ មានសិលាចារិក ចំនួន ៥៥០ផ្ទាំង មានរូបចម្លាក់ទូទាំងប្រទេសចំនួន២០៤០០ សិល្បករជាប់ថ្មចំនួន៦៤៦៥នាក់ មានអ្នករបាំចំនួន ១៦២២នាក់ មានបញ្ញាជនចំនួន ៣៨៥៧៣៧នាក់[5]។ របាយការណ៍របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ឆ្នាំ ២០១២ បានបង្ហាញថា**ប្រាសាទនៅក្នុងប្រទេសរបស់យើងមានចំនួន១១៩៨ ប្រាសាទ**[6]។ របាំក្បាច់បុរាណមាន ក្បាច់មូលដ្ឋាន៤៥០០ ជាតម្លៃខាងស្មារតី និងសោភ័ណស្ថិតនៅក្នុងចរន្តវប្បធម៌ទាំងពីរ គឺចរន្តបញ្ញាជន និងចរន្ត មហាជន ។ តម្លៃពិតទាំងពីរនេះបូកបញ្ចូលមក ទើបចេញជាអត្តសញ្ញាណពិតរបស់ខ្មែរ ។

## ៣-ការអភិវឌ្ឍវិស័យសិល្បៈវប្បធម៌ខ្មែរប្រកបដោយចីរភាព

ការកសាងសមត្ថភាព អភិវឌ្ឍន៍ធនធានមនុស្ស (បច្ចេកទេសនិងចំណេះដឹងទូទៅ) ការបញ្ជ្រាបមុខវិជ្ជា សញ្ញាណទូទៅស្តីពីទម្រង់សិល្បៈទស្សនីយភាពខ្មែរ តាមអនុវិទ្យាល័យ វិទ្យាល័យ វិទ្យាស្ថាន និងសកលវិទ្យាល័យ គឺជាអាទិភាព (Priority) ត្រូវតែរក្សាទុកការអប់រំវប្បធម៌សិល្បៈខ្មែរ ការផ្តល់ចំណេះដឹង និងបំណិនខាងវិស័យវប្ប ធម៌សិល្បៈមានដូចជា៖

គំនូរ របាំ ការហត្ថកម្ម ល្ខោន តន្ត្រី ចម្រៀង កំណាព្យ អក្សរសិល្ប៍ ជាមុខវិជ្ជាសំខាន់មួយក្នុងចំណោមមុខ វិជ្ជាដទៃទៀតនៅក្នុងប្រព័ន្ធអប់រំនៃកម្មវិធីសិក្សារបស់ក្រសួងអប់រំយុវជន និងកីឡា បង្កើតឱ្យមានវេទិកា (ឆាករបាំឬ ល្ខោនតូចៗ) នៅតាមគ្រឹះស្ថានសិក្សា សាលារៀន សាកលវិទ្យាល័យ ដូចជា៖

- ពង្រីកបរិមាណ និងគុណភាពគ្រូអប់រំសិល្បៈ
- ជម្រុញការលើកទឹកចិត្តដល់គ្រូអប់រំសិល្បៈ
- បង្កើនវគ្គបំពាក់បំប៉ន និងបណ្តុះបណ្តាលអ្នកជំនាញ
- ពង្រីកមធ្យោបាយផ្សព្វផ្សាយឱ្យទូលាយ
- ស្វែងរកថវិកាដើម្បីធានានូវនិរន្តរភាពនៃការអនុវត្ត
- បង្កើនទីផ្សារសិល្បៈទស្សនីយភាពក្នុង និងក្រៅប្រទេស
- លើកទឹកចិត្ត និងផ្តល់តម្លៃដល់អ្នកមានទេពកោសល្យខាងសិល្បៈលេចធ្លោ(ដុង)
- ការផ្សព្វផ្សាយចំណេះដឹងវប្បធម៌ និងគុណធម៌ជាតិ ដល់ជនជាតិខ្មែរទាំងឡាយដែលមានទឹកចិត្ត ស្រឡាញ់សិល្បៈវប្បធម៌ និងប្រពៃណីជាតិថា«ដួងព្រលឹង» គឺជា«អត្តសញ្ញាណ»របស់ជាតិយើង។

## ៤-ប្រសិទ្ធភាពនៃការអនុវត្តន៍ (Effectiveness of implementation)

ភាពសក្តិសិទ្ធិនៃសិល្បៈនាដសាស្ត្រឱ្យរីកចម្រើនទាំងរដ្ឋ និងឯកជនទៅបានលុះត្រាតែមានការចូលរួមជួយ ឧបត្ថម្ភគ្នាទៅវិញទៅមក ជួយបង្កលក្ខណៈសម្បត្តិងាយស្រួល និងផ្តល់សេរីភាពព្រមទាំងការលើកទឹកចិត្ត ដើម្បី បំពេញគ្នាទៅវិញទៅមក។ ការចូលរួមរបស់មហាជន ប្រជាជន បញ្ញាវន្ត គ្រូបង្រៀន សិស្សានុសិស្សទាំងអស់ និង ការយកចិត្តទុកដាក់លើកទឹកចិត្ត ឧបត្ថម្ភដល់ចលនាច្នៃប្រឌិត តែងនិពន្ធ ដែលជាប្រភពនៃការរីកចម្រើនខាងអក្សរ សិល្ប៍ និងសិល្បៈនាដកម្ម។

---

[5] - ដដែល-

[6] ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ របាយការណ៍ ឆ្នាំ២០១២

ការងារសិល្បៈវប្បធម៌ ជាការងារជំទូលាយណាស់ឱបក្រសោបជីវិតទាំងមូល ហើយគ្មានស្នាដៃណាដែលគ្មានមូលដ្ឋានចិត្តរំភើប និងមនុស្សធម៌ឡើយ។ ហេតុនេះទស្សនៈចង្អៀតចង្អល់ ទស្សនៈផ្តាច់មុខនិយមខាងផ្នែកវប្បធម៌ ឬទស្សនៈប្រមូលផ្តុំនិយមខាងផ្នែកសិល្បៈវប្បធម៌ជាតិ គឺជាគំនាបកៀបសង្កត់យ៉ាងធ្ងន់ធ្ងរដល់គំនិតច្នៃប្រឌិត និងឧបនិស្ស័យទេពកោសល្យរបស់មនុស្ស។ ដើម្បីឱ្យជំនាញមួយអភិវឌ្ឍន៍ទៅបាន ទាល់តែអ្នកធ្វើជំនាញនោះមានថវិកា មានការគ្រប់គ្រងល្អិតល្អន់ មានក្រមសីលធម៌ វិជ្ជាជីវៈ និងមានមនសិការជំនាញ៖

១- សមត្ថភាពជំនាញ

២- បទពិសោធន៍ជំនាញ

៣- ឧបនិស្ស័យជំនាញ

៤- ចិត្តស្រឡាញ់ជំនាញ

៥- ចិត្តពលីដើម្បីជំនាញ

ចំពោះសិល្បករ គ្មានទុក្ខវេទនាណាឱ្យខ្លាំងក្លាជាជាងការគ្មានឆាកសំដែងឡើយ។ យោងតាមសកម្មភាពដែលមានកន្លងមក និងក្នុងបំណងពង្រឹងផ្សព្វផ្សាយសិល្បៈវប្បធម៌ជាតិ ដែលធ្លាប់មានអរិយធម៌ដ៏រុងរឿងយូរលង់មកហើយនោះ និងដើម្បីទប់ទល់នឹងការហូរចូលចរន្តវប្បធម៌សិល្បៈបរទេសយើងនាំគ្នាធ្វើសកម្មភាព (រដ្ឋាភិបាល) តាមរយៈការគៀងគរវិនិយោគជារោងសម្តែងសិល្បៈឱ្យមានច្រើនទីតាំងដើម្បីងាយស្រួលក្នុងការបំផុសចលនាយុវជន មហាជនឱ្យចូលរួមក្នុងការបណ្តុះគំនិតឱ្យស្រឡាញ់បេតិកភណ្ឌវប្បធម៌សិល្បៈរបស់ខ្លួន ទើបយើងរកឃើញឡើងវិញនូវតម្លៃពិតខាងស្មារតីនៃសិល្បៈអរូបីរបស់ខ្លួន បន្តបណ្តុះបណ្តាលបំពាក់បំប៉នអត្តសញ្ញាណពិតរបស់ខ្មែរឱ្យកូនខ្មែរមានសាមគ្គីភាព មានភាពរុងរឿង និងវឌ្ឍនភាពខាងផ្លូវកាយ ផ្លូវចិត្តគំនិត ដើម្បីការវិវឌ្ឍដោយមានតុល្យភាព និងភាពសមរម្យរវាងបុគ្គល ធម្មជាតិ និងសង្គម។ បទបង្ហាញ ស្តីពី «ជ្រុងមួយនៃបេតិកភណ្ឌវប្បធម៌សិល្បៈអរូបីខ្មែរ» ជាផ្នែកមួយក្នុងការចូលរួមថែរក្សាការពារកេរមរតកដូនតាដែលមានលក្ខណៈពណ៌សម្បុរជាតិពិតក្នុងអត្ថន័យបុរាណមិនឃើតសម័យមិនបរទេស។

## **៥-សេចក្តីសន្និដ្ឋាន** (Conclusion)

ដើម្បីថែរក្សានូវបេតិកភណ្ឌសិល្បៈអរូបីទាំងអស់នោះបាន ត្រូវធ្វើឱ្យមានប្រយោជន៍រស់រវើកក្នុងជីវភាពរស់នៅរបស់ខ្មែរ នៅពេលដែលវប្បធម៌បរទេស មិនទាន់ក្លាយទៅជាជីវភាពរស់នៅរបស់ខ្មែរនៅឡើយ។ «**បើចង់ថែរក្សាឱ្យគង់វង្សនូវមរតកទាំងនោះ ទាល់តែធ្វើឱ្យប្រជាជនក្លាយទៅជាម្ចាស់នៃមរតកទាំងអស់នោះ បើចង់ឱ្យប្រជាជនក្លាយទៅជាម្ចាស់មរតក លុះត្រាតែធ្វើយ៉ាងណាឱ្យមរតកទាំងអស់នោះ នៅតែមានប្រយោជន៍ចំពោះជីវិតខ្មែរ**»។

ដូច្នេះការចូលរួមសិក្សាស្វែងយល់អំពីតម្លៃវប្បធម៌សិល្បៈខ្មែរ និងវប្បធម៌សិល្បៈផ្សេងៗដែលកំពុងជ្រៀតចូលមកក្នុងប្រទេសរបស់យើងមានទាំងវិជ្ជមាន និងអវិជ្ជមាន ការស្វែងរកដំណោះស្រាយ និងទិសដៅដើម្បីឱ្យវប្បធម៌សិល្បៈអរូបីខ្មែរ មានអត្ថិភាពនៅក្នុងពហុវប្បធម៌រួមគ្នាដោយស្មោះស្ម័គ្រក្នុងការអភិរក្សវប្បធម៌សិល្បៈរបស់ជាតិឱ្យបានគង់វង្ស និងការចូលរួមផ្តល់មតិក្នុងការអភិរក្សវប្បធម៌សិល្បៈអរូបីជាតិទៅតាមទំនោររីកចម្រើនដែលមានលក្ខណៈសមស្របតាមការរីកចម្រើនរបស់ប្រទេស, ចូលរួមលើកស្ទួយធ្វើឱ្យវប្បធម៌សិល្បៈខ្មែរ នៅតែមានអត្ថិភាពលេចត្រដែត ទោះបីវប្បធម៌សិល្បៈបរទេសជាច្រើនហូរចូលមកក្នុងប្រទេសយើងក៏ដោយ, ចូលរួមយ៉ាងសកម្មតាម

គ្រប់រូបភាពក្នុងការអប់រំធ្វើឱ្យមហាជនចេះបែងចែកច្បាស់លាស់រវាងវប្បធម៌សិល្បៈខ្មែរដោយមិនធ្វើឱ្យច្របូកច្របល់នាំឱ្យបាត់ប្រភពដើមនៃវប្បធម៌សិល្បៈរបស់ខ្លួន។ ដូច្នេះមរតកវប្បធម៌សិល្បៈអរូបីខ្មែរ ជាជ្រុងមួយតូចជួយពង្រឹងអត្តសញ្ញាណជាតិខ្មែរ និងរួមចំណែកអភិវឌ្ឍន៍សង្គមខ្មែរមាតុភូមិកម្ពុជាឱ្យរីកចម្រើនរុងរឿង។ វប្បធម៌ជាគ្រឹះនៃការអភិវឌ្ឍន៍សង្គម ។

## ឯកសារពិគ្រោះ


១) **ហ៊ុន សែន** សារលិខិត ថ្ងៃទី៨ មិថុនា ២០១៧

២) **ត្រឹង ងា** ប្រវត្តិសាស្ត្រខ្មែរ ឆ្នាំ១៩៧៦

៣) Pich Tum Kravel Khmer Dances, 2001

៤) KEO NArum APSARA DANCE, 2003

៥) Pich Tum Kravel KHMER PERFORMING ARTS, 2003

៦) **ពេជ្រ ទុំក្រវិល** តន្ត្រីរបាំនិងល្ខោន ឆ្នាំ២០១០

៧) **គណៈកម្មាការវប្បធម៌កម្ពុជា** ប្រវត្តិសាស្ត្រកម្ពុជា ឆ្នាំ២០០៨

៨) **វង់ ជុន** ជីវិតខ្មែរនិងល្ខោនខ្មែរ ឆ្នាំ២០០៩

៩) **ឆេង ផុន** គោលទស្សនៈធំៗ ចំពោះវប្បធម៌ខ្មែរ និងការអភិវឌ្ឍ ឆ្នាំ២០០០

១០) **សេង គឹមលី** ប្រវត្តិសិល្បៈខ្មែរ ឆ្នាំ២០០២

១១) **ពុទ្ធសាសនបណ្ឌិត្យ** វចនានុក្រមភាគ១-២ ឆ្នាំ១៩៦៧ បោះពុម្ពលើកទី៥ ទំព័រ១៣៤០

១២) **វ៉ា សុវណ្ណារ័ត្ន** ស្ថាបត្យកម្មពិភពលោក ឆ្នាំ២០០៧

១៣) **ម៉ាយឃើលវិកឃើរី** ប្រវត្តិសាស្ត្រកម្ពុជា ឆ្នាំ២០០២

១៤) **ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ** បញ្ជីសារពើភណ្ឌអរូបី ឆ្នាំ២០១៨

១៥) **ជីវ តាក្វាន់** កំណត់ហេតុ ឆ្នាំ១៩៧៣